**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ

---

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ

-បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើត និង ដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព

-យោងតាមស្មារតីនៃអង្គប្រជុំអន្តរក្រសួង កាលពីថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៥

-យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងធ្វើការណែនាំឱ្យអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារសំរាប់មន្ត្រីរាជការស៊ីវិល ដែលកំពុងបំពេញការងារនៅតាមគំរោងផ្សេងៗរបស់ក្រសួង-ស្ថាប័ន ដែលធ្វើហិរញ្ញប្បទាន ដោយដៃគូអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាល ដើម្បីឱ្យមានភាពរលូន និង ឆ្លើយតបទៅនឹងអាទិភាពរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ២
## លក្ខខណ្ឌនៃការអនុវត្ត

**មាត្រា ២.-**

ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ដែលធ្វើហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ មិនត្រូវចាត់ទុកជាប្រាក់បៀវត្សរបស់មន្ត្រីរាជការស៊ីវិលទេ ។

**មាត្រា ៣.-**

ក្រសួង ស្ថាប័នទាំងអស់ ត្រូវចាត់វិធានការ និង ជំរុញលើកទឹកចិត្តដៃគូអភិវឌ្ឍន៍ទាំងអស់ ឱ្យបង្វែរប្រាក់ឧបត្ថម្ភបន្ថែមប្រចាំខែ ដែលកំពុងតែអនុវត្តនាពេលបច្ចុប្បន្ននេះ មកគាំទ្រដល់ការអនុវត្តគំរោងកន្សោមអាទិភាព នៅតាមក្រសួង-ស្ថាប័ន និង ខេត្ត-ក្រុងនីមួយៗ ក្នុងរូបភាព ២ ដូចខាងក្រោម :

- ជួយបង្កើនចំនួនសមាជិកកន្សោមអាទិភាព ក្នុងវិស័យអាទិភាពពាក់ព័ន្ធនឹងការកាត់បន្ថយភាពក្រីក្រ និង ការងារកំណែទំរង់រដ្ឋ ដែលការអនុវត្តចាំបាច់ត្រូវគោរពតាមគោលការណ៍ និង យន្តការនៃកម្មវិធីកន្សោមអាទិភាព ។
- ក្នុងករណីចាំបាច់ ដោយមានការពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និង មានការឯកភាពពីដៃគូអភិវឌ្ឍន៍ មន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅក្នុងគំរោងទាំងនោះ អាចទទួលបានប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ក្នុង ១ ខែ តាមចំនួន ដូចខាងក្រោម :

| | | | |
|---|---|---|---|
| -ថ្នាក់អគ្គនាយក | ត្រូវទទួលបានចំនួន | ១.៦០០.០០០ | រៀល |
| -ថ្នាក់អគ្គនាយករង | ត្រូវទទួលបានចំនួន | ១.២៨០.០០០ | រៀល |
| -ថ្នាក់ប្រធាននាយកដ្ឋាន | ត្រូវទទួលបានចំនួន | ១.០៨០.០០០ | រៀល |
| -ថ្នាក់អនុប្រធាននាយកដ្ឋាន | ត្រូវទទួលបានចំនួន | ៨៨០.០០០ | រៀល |
| -ថ្នាក់មន្ត្រីគ្រប់គ្រងរដ្ឋបាល | ត្រូវទទួលបានចំនួន | ៧២០.០០០ | រៀល |
| -ថ្នាក់ប្រធានការិយាល័យ | ត្រូវទទួលបានចំនួន | ៤៨០.០០០ | រៀល |
| -ថ្នាក់អនុប្រធានការិយាល័យ | ត្រូវទទួលបានចំនួន | ៣៨៤.០០០ | រៀល |
| -ថ្នាក់មន្ត្រីក្រមការ | ត្រូវទទួលបានចំនួន | ៣២០.០០០ | រៀល |
| -ថ្នាក់លេខាធិការ | ត្រូវទទួលបានចំនួន | ២០០.០០០ | រៀល ។/ |

**មាត្រា ៤.-**

ការប្រើប្រាស់ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ដូចមានចែងក្នុងមាត្រា ៣ ខាងលើ ត្រូវបញ្ចប់ នៅពេលដែលការធ្វើហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ត្រូវបានបញ្ចប់ ឬ គំរោងត្រូវបានបញ្ចប់ ។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។៚

*ធ្វើនៅរាជធានីភ្នំពេញ [illegible] ឆ្នាំ ២០០៥*

ហ៊ុន សែន

**បានយកសេចក្តីជម្រាបជូនសម្តេច នាយករដ្ឋមន្ត្រី**

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

និងជា ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

សុខ អាន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- អគ្គស្នងការដ្ឋានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- ដូចមាត្រា ៦
- ឯកសារ-កាលប្បវត្តិ

សេចក្តីព្រាង

## តារាង បៀវត្ស - ប្រាក់បំណាច់មុខងារ និង កន្សោមអាទិភាព

| មុខងារ | ក្របខ័ណ្ឌ | បៀវត្សមូលដ្ឋាន | | ប្រាក់បំណាច់មុខងារ | | PMG | សរុបជារៀល | | សរុបជាដុល្លារ | | ប្រាក់បន្ថែមពីគំរោងផ្សេងៗ | សរុបទូទៅ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | Min. | Max. | Min. | Max. | | Min. | Max. | Min. | Max. | | Min. | Max. |
| អគ្គនាយក | ក១ | 150,420 | 189,750 | 735,000 | 929,000 | 0 | 885,420 | 1,118,750 | 221 $ | 279 $ | 400 $ | 621 $ | 679 $ |
| អគ្គនាយករង | ក២ | 124,545 | 168,015 | 645,000 | 815,000 | 0 | 769,545 | 983,015 | 192 $ | 245 $ | 320 $ | 512 $ | 565 $ |
| ប្រធាននាយកដ្ឋាន | ក២ | 124,545 | 168,015 | 620,000 | 786,000 | 0 | 744,545 | 954,015 | 186 $ | 238 $ | 270 $ | 456 $ | 508 $ |
| អនុប្រធាននាយកដ្ឋាន | ក៣ | 108,675 | 146,625 | 540,000 | 706,000 | 0 | 648,675 | 852,625 | 162 $ | 213 $ | 220 $ | 382 $ | 433 $ |
| មន្ត្រីគ្រប់គ្រងរដ្ឋបាល | ក៣ | 108,675 | 146,625 | 65,000 | 113,700 | 520,000 | 693,675 | 780,325 | 173 $ | 195 $ | 180 $ | 353 $ | 375 $ |
| ប្រធានការិយាល័យ | ខ១ | 106,260 | 132,825 | 78,100 | 136,600 | 350,000 | 534,360 | 619,425 | 133 $ | 154 $ | 120 $ | 253 $ | 274 $ |
| អនុប្រធានការិយាល័យ | ខ២ | 86,940 | 117,300 | 61,400 | 107,400 | 350,000 | 498,340 | 574,700 | 124 $ | 143 $ | 96 $ | 220 $ | 239 $ |
| មន្ត្រីក្រមការ | ខ៣ | 73,900 | 102,465 | 36,500 | 64,000 | 350,000 | 460,400 | 516,465 | 115 $ | 129 $ | 80 $ | 195 $ | 209 $ |
| នាយលេខាធិការ | គ១ | 73,140 | 90,390 | 24,000 | 42,100 | 190,000 | 287,140 | 322,490 | 71 $ | 80 $ | 50 $ | 121 $ | 130 $ |
| លេខាធិការដើមខ្សែ | គ២ | 59,685 | 80,385 | 24,000 | 42,100 | 190,000 | 273,685 | 312,485 | 68 $ | 78 $ | 50 $ | 118 $ | 128 $ |
| លេខាធិការ | គ៣ | 51,750 | 69,690 | 24,000 | 42,100 | 190,000 | 265,750 | 301,790 | 66 $ | 75 $ | 50 $ | 116 $ | 125 $ |